# អលព្កនីយធម៌

រៀបរៀងដោយ

ភិក្ខុ ងិន ភេន ឥន្ទប្បញ្ញោ

បោះពុម្ពចែកជាធម្មទាន
ក្នុងឱកាសបុណ្យទក្ខិណានុប្បទាន១០០ថ្ងៃ
កាលពីថ្ងៃសៅរ៍ ទី១២ មិនា ២០០៥

នៅ**វត្តពោធិវង្ស** ប្រទេសបារាំង

ព.ស. ២៥៤៨ គ.ស. ២០០៥

ដើម្បីជាបុណ្យកុសលផង ដើម្បីទុកជាទីរលឹកផង ខ្ញុំបានសុំយកធម្មទេសនា ដែលព្រះសង្ឃសម្តែងរួចហើយ ពីពេលមុន មកបោះពុម្ពចែកជាធម្មទាន ក្នុងឱកាសបុណ្យទក្ខិណានុប្បទាន១០០ថ្ងៃ នៅថ្ងៃសៅរ៍ ទី១២ មិនា ២០០៥ នាវត្តពោធិវង្ស ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះសង្ឃ និង ញាតិមិត្រ ដែលបានជួយផ្គត់ផ្គង់ ធ្វើឲ្យសៀវភៅនេះ បានសម្រេចដូចបំណង ។

សូម អ្នកឡេ (សរិតា) ជាភរិយា ជាមាតា ជាជីដូន អនុមោទនា យកឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត កុំបីខាន ។

ថ្ងៃសៅរ៍ ទី១២ មិនា ២០០៥

ខៀវ ឡេង
និង កូន ចៅ

## **ធម្មទេសនា**

សម្តែងដោយ ភិក្ខុ ងិន ភេន ឥន្ទប្បញ្ញោ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៚**

ថ្ងៃពុធ ៨ ធ្នូ ឆ្នាំ២០០៤ ។ ថ្ងៃនេះ លោក ខៀវ ឡេង ព្រមទាំងកូនចៅ និង អស់លោក អ្នកជាញាតិមិត្រ បានកំពុងតែប្រារព្ធ ធ្វើបុណ្យទក្ខិណានុប្បទាន ឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធ នៃឧបាសិកា ម៉ៅ សរិតា ដែលត្រូវជាភរិយា ជាមាតា ជាជីដូន និង ត្រូវជាញាតិមិត្រ ដែលទើបនឹងទទួលមរណភាពទៅថ្មីៗនេះ គឺទទួលមរណភាព កាលពីថ្ងៃសៅរ៍ ទី៤ ធ្នូ នៅវេលាម៉ោង៩.០០ព្រឹក ដោយជរាព្យាធិ គឺមិនបានជាមានជម្ងឺអ្វីធ្ងន់ធ្ងរមកពីមុនទេ ស្រាប់តែទទួលទានដំណេកទៅ ក៏ស្លាប់បណ្តោយទៅតែម្តង គឺស្លាប់ដោយស្ងប់ស្ងៀមយ៉ាងស្រួល ពុំមាននរណាបានដឹងឬនឹកស្មានទុកជាមុនសោះ ។

បន្ទាប់ពីមរណភាពទៅ គ្រួសារ បាននិមន្តព្រះសង្ឃបង្សុកូល និងចាត់ចែងយកសពទៅតម្កល់ទុកនៅកន្លែងតម្កល់សព បង្សុកូលតាមប្រពៃណី លុះដល់មកថ្ងៃពុធ៨ធ្នូនេះ បានដង្ហែសពចេញពីកន្លែងតម្កល់នោះ ឆ្ពោះទៅកាន់វត្តពោធិវង្ស ប្រារព្ធធ្វើបុណ្យទក្ខិណានុប្ប-ទាន នមស្សការ សមាទានសីល ចំរើនបរិត្ត បង្សុកូល និងសម្តែងធម៌ទេសនា ។ អាត្មាភាព ទទួលភារៈសម្តែងធម៌ទេសនាថ្ងៃហ្នឹង ។ ហើយថ្ងៃស្អែក ក៏នឹងដង្ហែសពចេញពីវត្ត ទៅបូជានៅ Père lachaise



មានកម្មវិធីសម្តែងធម៌នៅទីនោះទៀត លុះដល់ថ្ងៃសៅរ៍ ១១ ធ្នូ នឹងមានធ្វើបុណ្យទក្ខិណានុប្បទាន ៧ ថ្ងៃ សម្តែងធម៌ទេសនាទៀត នៅវត្តពោធិវង្ស ។

វេលានេះ អាត្មាភាព នឹងសម្តែងព្រះធម្មទេសនា ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដែលមានកត់ត្រាទុកក្នុងគម្ពីរសុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត មានឈ្មោះហៅថា អលព្ភនីយដ្ឋាន ឬ អលព្ភនីយធម៌ ។ អលព្ភនីយធម៌ ប្រែថា ធម៌ដែលបុគ្គល មិនគប្បីបានតាមប្រាថ្នា ។ បុគ្គលនោះ គឺជានរណា ? **សមណេន វា** ជាសមណៈក្តី **ព្រាហ្មណេន វា** ជាព្រាហ្មណ៍ក្តី **ទេវេន វា** ជាទេវតាក្តី **មារេន វា** ជាមារក្តី **ព្រហ្មុនា វា** ជាព្រហ្មក្តី **កេនចិ វា លោកស្មឹ** ជាបុគ្គលណាមួយក្នុងលោកក្តី មិនគប្បីបានតាមប្រាថ្នា គឺប្រាថ្នាឲ្យបានដូចចិត្តខ្លួន ឬដូចបំណងរបស់ខ្លួនមិនបានទេ ។ អលព្ភនីយធម៌នោះ មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? អលព្ភនីយធម៌នោះ មាន៥យ៉ាងគឺ :

១-របស់ដែលមានចាស់(ជរា) ជាធម្មតា បុគ្គលប្រាថ្នាកុំឲ្យចាស់ ។

២-របស់ដែលមានជម្ងឺ(ព្យាធិ) ជាធម្មតា បុគ្គលប្រាថ្នាកុំឲ្យមានជម្ងឺ ។

៣-របស់ដែលមានស្លាប់(មរណ) ជាធម្មតា បុគ្គលប្រាថ្នាកុំឲ្យមានស្លាប់ ។

៤-របស់ដែលមានការអស់ទៅ ទ្រុឌទ្រោមទៅ(ខយ) ជាធម្មតា បុគ្គលប្រាថ្នាកុំឲ្យមានការអស់ទៅ ទ្រុឌទ្រោមទៅ ។

៥-របស់ដែលមានការវិនាសសាបសូន្យទៅ (នស្ស) ជាធម្មតា បុគ្គលប្រាថ្នាកុំឲ្យមានការវិនាស កុំឲ្យមានការសាបសូន្យទៅ ។

ធម៌ដែលមានលក្ខណៈទាំង៥យ៉ាងនេះ បុគ្គលជាសមណៈក្តី ជាព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុងលោកក្តី មិនគប្បីបានតាមប្រាថ្នាទេ ។

របស់ដែលមានលក្ខណៈ ៥ យ៉ាងគឺ ចាស់ ឈឺ ស្លាប់ ទ្រុឌទ្រោម វិនាសសាបសូន្យទៅជាធម្មតានោះ តើបានដល់របស់អ្វីខ្លះទៅ ? សូមជម្រាបថា របស់អ្វីក៏ដោយ ដែលកើតឡើងហើយ ទោះបីមានវិញ្ញាណក្តី មិនមានវិញ្ញាណក្តី នៅក្នុងលោកយើងនេះ ឬនៅក្នុងលោកដទៃក្តី របស់ទាំងអស់នោះ សុទ្ធតែមានចាស់ ឈឺ ស្លាប់ ទ្រុឌទ្រោម វិនាសសាបសូន្យទៅវិញទាំងអស់ នឹងរៀបរាប់ជាឈ្មោះរបស់នោះមិនអស់ទេ ប៉ុន្តែ បើនិយាយតាមគោលពុទ្ធសាសនា បានដល់សង្ខារធម៌២ យ៉ាងគឺ :

១-**ឧប្បាទិន្នកសង្ខារ** សង្ខារមានចិត្ត មានវិញ្ញាណ ឧទាហរណ៍ មនុស្ស សត្វ ជាដើម ។

២-**អនុប្បាទិន្នកសង្ខារ** សង្ខារមិនមានចិត្ត មិនមានវិញ្ញាណ ឧទាហរណ៍ ផ្ទះ រទេះ រថយន្ត ជាដើម ។



សង្ខារធម៌ទាំង ២ យ៉ាងនេះ សុទ្ធតែមាន ចាស់ ឈឺ ស្លាប់ ទ្រុឌទ្រោម វិនាសសាបសូន្យទៅវិញដូចគ្នាទាំងអស់ គ្រាន់តែមានប្លែកគ្នាខ្លះ បើមនុស្សឈឺចេះស្រែកចេះថ្ងូរ បើផ្ទះឈឺមិនចេះស្រែកចេះថ្ងូរទេ គ្រាន់តែទ្រុឌទ្រោមទៅ បើមនុស្សស្លាប់ គឺអស់ដង្ហើម បើផ្ទះស្លាប់មិនចាំបាច់មើលដង្ហើមទេ គឺវាពុកអស់រុះចោលទៅ... ។

មនុស្សយើងជាសង្ខារធម៌ដែរ ដូចនេះ ត្រូវតែមានចាស់ ឈឺ ស្លាប់ ទ្រុឌទ្រោម វិនាសសាបសូន្យទៅ ដូចសង្ខារឯទៀតដែរ គេនឹងគេចទៅសម្ងំនៅក្នុងអាកាសក្តី ក្នុងសមុទ្រក្តី ក្នុងរូងភ្នំក្តី ឬទីដទៃណាទៀតក្តី ឲ្យរួចផុតពីចាស់ ឈឺ ស្លាប់ ទ្រុឌទ្រោម វិនាសសាបសូន្យទៅ មិនបានជាដាច់ខាត ។ ព្រោះហេតុដូចនោះហើយ បានជា ឧបាសិកា ម៉ៅ សរិតា ត្រូវតែជួបនឹងសេចក្តីស្លាប់ បើមិនឆាប់ក៏យូរ នឹងប្រាថ្នាកុំឲ្យមានស្លាប់ មិនបានជាដាច់ខាត បានជាព្រះលោកនាថ ត្រាស់ហៅថា អលព្ភនីយធម៌ ។

មនុស្សគ្រប់រូប ក្មេងក្តី ចាស់ក្តី ល្ងង់ក្តី ចេះដឹងក្តី ទ័លក្រក្តី មានទ្រព្យស្តុកស្តម្ភក្តី រាស្ត្រក្តី នាម៉ឺនក្តី ស្តេចសោយរាជ្យក្តី គ្រហស្ថក្តី បព្វជិតក្តី បានសម្រេចធម៌ជាព្រះអរហន្តក្តី បានត្រាស់ដឹងធម៌ជាព្រះពុទ្ធក្តី មនុស្សទាំងអស់នោះ នឹងប្រាថ្នា កុំឲ្យមានចាស់ ឈឺ ស្លាប់ កុំឲ្យមាន ទ្រុឌទ្រោម វិនាសសាបសូន្យទៅ មិនបានសម្រេចទេ គេត្រូវតែមាន ចាស់ ឈឺ ស្លាប់ មានទ្រុឌទ្រោម វិនាសសាបសូន្យទៅ ដូចគ្នាទាំងអស់ គ្រាន់តែមានការប្លែកគ្នាដូចតទៅនេះ :

បុគ្គលអ្នកមិនបានរៀនសូត្រ មិនចេះដឹងធម៌ មិនបដិបត្តិធម៌ មិនបានសម្រេចធម៌ (គឺនៅជាបុថុជ្ជន) តែងប្រាថ្នា កុំឲ្យមានចាស់ ឈឺ ស្លាប់ កុំឲ្យមានទ្រុឌទ្រោម វិនាសសាបសូន្យទៅ កាលបើគេមិនបានដូចប្រាថ្នា គេតែងកើតទុក្ខ យំសោកបោកខ្លួន... ។

ចំណែកបុគ្គលអ្នកបានរៀនសូត្រ ចេះដឹងធម៌ បដិបត្តិធម៌ បានសម្រេចធម៌ (គឺជាព្រះអរិយៈ) លោកមិនមានប្រាថ្នាដូចនោះឡើយ លុះពេលវាមកដល់ លោកមិនកើតទុក្ខ យំសោកបោកខ្លួនទេ ព្រោះនេះជាធម្មតា ឬជាច្បាប់របស់សង្ខារធម៌ ។

ព្រះបាទមុណ្ឌៈ នៃក្រុងបាតលីបុត្រ ជាបុគ្គលល្ងង់ច្រើន ប្រាថ្នាច្រើន កាលព្រះអគ្គមហេសី ភទ្រាទេវី សោយព្រះទិវង្គត ព្រះអង្គបានឲ្យគេយកព្រះសពនៃព្រះមហេសីទៅតម្កល់ទុកកោដ្ឋដែក ដែលពេញដោយប្រេង ព្រះអង្គកើតទុក្ខយំសោកបោកខ្លួន មិនបំពេញព្រះរាជករណីយកិច្ច មិនសោយព្រះស្ងោយ ពេលក្រោយមកដោយបានទ្រង់ព្រះសណ្ដាប់ អលព្ភនីយធម៌ ពីសំណាក់នៃព្រះនារទៈ ព្រះអង្គ ក៏ភ្លឺស្វាង ហើយបានឲ្យគេយកសពព្រះមហេសីទៅថ្វាយព្រះភ្លើង... ។

បុគ្គលណា ល្ងង់ច្រើន ប្រាថ្នាច្រើន បុគ្គលនោះ កើតទុក្ខច្រើន
បុគ្គលណា ល្ងង់តិច ប្រាថ្នាតិច បុគ្គលនោះ កើតទុក្ខតិច
បុគ្គលណា អស់ល្ងង់ អស់ប្រាថ្នា បុគ្គលនោះ អស់ទុក្ខ ។

លោកអ្នក សប្បុរសទាំងឡាយ ម្យ៉ាងទៀត មានរឿងដែលគួរ



ពិចារណាមួយគឺ មនុស្សយើងមានចាស់ ឈឺ ស្លាប់ ជាធម្មតា ហើយចូលចិត្តស្វែងរកតែរបស់ដែលមាន ចាស់ ឈឺ ស្លាប់ ជាធម្មតានោះ មិនចូលចិត្តស្វែងរករបស់ដែលមិនចាស់ មិនឈឺ មិនស្លាប់ផងទេ ។ របស់ដែលមាន ចាស់ ឈឺ ស្លាប់ ជាធម្មតា គឺ ប្ដី ប្រពន្ធ មាស ប្រាក់ ទ្រព្យសម្បត្តិ... ឯរបស់ដែលមិនចាស់ មិនឈឺ មិនស្លាប់ គឺព្រះធម៌។ ការស្វែងរកទ្រព្យសម្បត្តិ ព្រះពុទ្ធ មិនបានហាមឃាត់ ទុកឲ្យយើងទ័លក្រទេ ប៉ុន្តែព្រះអង្គ ណែនាំឲ្យយើងស្វែងរកព្រះធម៌ យើងស្វែងរកតែរបស់ដែលមាន ចាស់ ឈឺ ស្លាប់ យើងត្រូវតែជួបនឹងចាស់ ឈឺ ស្លាប់ ជាដរាប លុះណាតែយើង ស្វែងរករបស់មិនចាស់ មិនឈឺ មិនស្លាប់ផង ទើបយើងអាច រំដោះខ្លួនផុតពីចាស់ ឈឺ ស្លាប់ ទៅបាន ។

លោក អ្នក សប្បុរសទាំងឡាយ ការសម្ដែងធម៌ទេសនា ល្មមសមគួរដល់ពេលវេលាហើយ ប៉ុន្តែមុននឹងបញ្ចប់ធម៌ ក្នុងនាមគ្រួសារនៃសព អាត្មាភាព សូមឧទ្ទិសបុណ្យកុសលជូនចំពោះ ឧបាសិកា ម៉ៅ សរិតា សូមវិញ្ញាណនៃលោកស្រី អនុមោទនា ទទួលយកឥដ្ឋមនុញ្ញផល ហើយសោយសេចក្ដីសុខ សន្តិភាព តាមសមគួរចុះ ។

ធម្មទេសនា សង្ខេបេន និដ្ឋិតា

ព្រះធម៌ទេសនា ចប់ដោយសង្ខេប ត្រឹមប៉ុណ្ណោះ ឯវំ ៕

ថ្ងៃពុធ ទី៧ ខែធ្នូ ២០០៤

## ធម្មទេសនា

អាត្មភាព សូមចំរើនពរ លោក អ្នក សប្បុរសទាំងឡាយ !

ក្នុងឱកាសបុណ្យឈាបនកិច្ច ឧបាសិកា ម៉ៅ សរិតា មានកម្មវិធីសម្តែងធម៌ទេសនា អាត្មាភាព ទទួលភារៈជាអ្នកសម្តែងចែកជូនតាមការនិមន្តរបស់ម្ចាស់បុណ្យ ។ ហេតុនេះ សូមលោក អ្នក ពុទ្ធបរិស័ទទាំងឡាយ តាំងចិត្តស្តាប់ធម៌ទេសនា ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដោយសេចក្តីគោរព អាត្មាភាព នឹងវិសជ្ជនាធម៌ជូនដូចតទៅនេះ :

សូមចំរើនពរ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** ។

បន្ទាប់អំពីបទនមស្សការនេះទៅ អាត្មាភាព នឹងសម្តែងធម៌ទេសនា តាមពុទ្ធភាសិត ដែលបានលើកមកតាំងទុកខាងដើម **តយោមេ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ភ្លើងនេះមាន ៣ យ៉ាង ។ **កតមេ តយោ** ភ្លើងនេះមាន ៣ យ៉ាង តើដូចម្តេច ។ **រាគគ្គិ ទោសគ្គិ មោហគ្គិ** ភ្លើងគឺរាគៈ១ ភ្លើងគឺទោសៈ១ ភ្លើងគឺមោហៈ១។

**រាគគ្គិ ទហតិ មច្ចេ     រត្តេ កាមេសុ មុច្ឆិតេ**<br>
**ទោសគ្គិ បន ព្យាបន្នេ     នរេ បាណាតិបាតិនោ**<br>
**មោហគ្គិ បន សម្មូឡ្ហេ     អរិយធម្មេ អកោវិទោ**(១) ។

---

(១)-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ ភ.៥៣ ទំព័រ ១២២



ភ្លើងគឺរាគៈ រមែងដុតពួកសត្វដែលត្រេកត្រអាលជ្រប់នៅក្នុង កាម ចំណែកភ្លើងគឺទោសៈ រមែងដុតពួកជនដែលមានចិត្តព្យាបាទជាអ្នកសម្លាប់សត្វ ឯភ្លើងគឺមោហៈ រមែងដុតពួកសត្វដែលវង្វេងមិនឈ្លាសវៃក្នុងអរិយធម៌ ។

ពួកសត្វដែលមិនស្គាល់ភ្លើងទាំងនេះ ជាអ្នកត្រេកអរក្នុងសក្កាយ(ឧបាទានក្ខន្ធ៥) រមែងញ៉ាំងភ្លើងទាំងនោះឲ្យចំរើន ទាំងញ៉ាំងនរក តិរច្ឆាន កំណើតអសុរកាយ និង បិត្តិវិស័យ ឲ្យចំរើន មិនផុតចាកចំណងមារបានឡើយ ។

លោក អ្នក ពុទ្ធបរិស័ទទាំងឡាយ ភ្លើងគឺជាធម្មជាតិដែលមានកំដៅក្តៅពន់ពេក ប៉ុន្តែ រាគៈជាធម្មជាតិមានកំដៅអាចក្តៅរោលរាលដុតរូបរាងកាយសត្វលោកខ្លាំងជាងកំដៅភ្លើងទៅទៀត ។

ភ្លើងដែលឆេះរោលរាលឡើង បណ្តាលឲ្យមានពន្លឺកំដៅនិងចំហាយ អាចឲ្យយើងមើលឃើញបាន បើប៉ះនឹងរាងកាយយើង វាបណ្តាលឲ្យក្តៅរលាកឬឆេះឆ្លូលជាមិនខាន ប៉ុន្តែ ភ្លើងនេះ កាលណាយើងប្រយ័ត្នវាឲ្យមែនទែន វាមិនអាចឆេះឬរលាកបានឡើយ បើកាលណាវាឆេះរលាកដោយមិនប្រុងប្រយ័ត្នវិញ វាក៏ធ្វើឲ្យក្តៅរលាកតែមួយភ្លែតប៉ុណ្ណោះ រួចទៅក៏បាត់ទៅវិញ ចំណែកខាងភ្លើងគឺរាគៈ (រាគគ្គិ) វាមានកំដៅហើយអាចឆេះឆ្លូលរោលរាលដុតបង្ហុយរាងកាយ សត្វលោកពីខាងក្នុងឲ្យអន្ទះសាក្រហល់ក្រហាយ មិនអាចរលត់ទៅ

វិញបានឡើយ គឺគ្មានអ្វីក្តៅជាជាងភ្លើងរាគៈនេះឡើយ សមដូចពុទ្ធភាសិតសម្តែងថា **នត្ថិ រាគសមោ អគ្គិ** ភ្លើងស្មើដោយរាគៈ មិនមានឡើយ ។

ឯភ្លើងទោសៈ រមែងដុតពួកជនដែលមានចិត្តព្យាបាទ ជាអ្នកសម្លាប់សត្វ ។ តើភ្លើងទោសៈនោះកើតមកពីណា ? ភ្លើងទោសៈកើតមកអំពីសេចក្តីក្រោធជាសមុដ្ឋាន សមដូចពុទ្ធភាសិតសម្តែងថា **ទោសោ កោធសមុដ្ឋានោ** ទោសៈ មានសេចក្តីក្រោធជាសមុដ្ឋាន ។ ទោសៈបានដល់កំហឹងខឹងក្នុងចិត្ត នាំឲ្យធ្វើកំហុសផ្សេងៗជាច្រើនប្រការ មានហេតុប្រភព ឬដើមចមដំណើរទំនងកើតចេញមកពីសេចក្តីក្រោធ ។ កាលណាមានអារម្មណ៍ណា ឬព្រឹត្តិការណ៍ ហេតុភេទ ពាក្យសំដី អំពើនានាពីខាងក្រៅខ្លួន មកប៉ះនឹងចិត្តឬអាយតនៈខាងក្នុង មិនបណ្តាលចិត្តឲ្យសប្បាយរីករាយត្រេកអរទៅកើត ចិត្តនេះក៏ក្រោធខឹងបណ្តាលឲ្យមានទោសៈឡើង ។ កាលបុគ្គលមានទោសៈហើយៗមិនបានយកវិចារណញ្ញាណមកធ្វើជាឧបករណ៍ ដើម្បីត្រិះរិះរកខុសត្រូវ ល្អអាក្រក់ទៅអនាគតថានឹងមានផលយ៉ាងណាៗហើយ ចិត្តក្រោធដែលបង្កើតទោសៈនេះ ក៏នាំរាងកាយឲ្យធ្វើសកម្មភាពផ្សេងៗភ្លាម ហើយក៏បណ្តាលឲ្យមានកំហុសរឹតតែធ្ងន់ឡើងៗតទៅទៀត ព្រោះបុគ្គលចងក្រោធនោះមិនព្រមរសាយ ដូចពុទ្ធភាសិតថា **ឧបនាហ** ចងក្រោធទុក នេះជាឧបកិលេស ដែលជាគ្រឿងសៅហ្មងរបស់សត្វលោក ។



រីឯភ្លើងមោហៈ រមែងដុតពួកសត្វដែលវង្វេង មិនឈ្លាសវៃក្នុងអរិយធម៌ ។

វង្វេងគឺភាន់គំនិត មិនស្គាល់ធម៌របស់ព្រះអរិយៈ គឺជាធម៌ពិតសំដៅយកអរិយសច្ចទាំង៤ ។ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គ បានត្រាស់ដឹងនូវចតុរារិយសច្ច មិនមែនត្រាស់ដឹងនូវអ្វីក្រៅអំពីអរិយសច្ចៈទាំង៤នេះឡើយ ។ របស់ពិតយ៉ាងប្រសើរ ហៅថា អរិយសច្ចៈ ជារបស់ពិតនៃព្រះអរិយៈ របស់ពិតដែលឆ្ងាយចាកសត្រូវ គឺកិលេសដែលជាគ្រឿងសៅហ្មងក្នុងចិត្តរបស់បុគ្គលក្នុងលោក របស់ពិតដែលធ្វើបុថុជ្ជនឲ្យក្លាយទៅជាអរិយៈ ។ អរិយសច្ច៤ ល្អវិសេសលើសជាងសច្ចៈទាំងឡាយដទៃ ព្រោះសច្ចៈយ៉ាងដទៃគ្រាន់តែឲ្យបានសម្រេចត្រឹមជាតិនេះនិងជាតិមុខប៉ុណ្ណោះ មិនមែនឲ្យសម្រេចដល់បរមត្ថប្រយោជន៍បានទេ ឯអរិយសច្ច៤ អាចឲ្យសម្រេចដល់បរមត្ថប្រយោជន៍ទៀតផង។ ដែលថាជារបស់ពិតនោះ ក៏ព្រោះតែមិនប្រែប្រួលទៅជាយ៉ាងដទៃ បើជាទុក្ខក៏ជាទុក្ខពិតៗ មិនអាចទៅជាសុខបានទេ ។ តណ្ហា(ចំណង់) ជាមូលហេតុឲ្យទុក្ខកើត ក៏កើតពិត ។ កាលបានពិចារណាទៅហើយ ក៏ទៀងតែឃើញថា ជារបស់ពិតគ្រប់យ៉ាង បើត្រឡប់ប្រែក្លាយវិញបាន ក៏មិនមែនជាអរិយសច្ចឡើយ ឯអរិយសច្ចទាំង៤នេះ ជាបរមត្ថ មិនមានខ្លួន មិនមានប្រាណ គ្រាន់តែជានាមធម៌ តែមានអំណាចអាចឲ្យផលយ៉ាងពិសេសដល់អ្នកបដិបត្តិ ។ ព្រះពុទ្ធ ជាម្ចាស់ កាលបាន

ត្រាស់ដឹង ក៏ព្រោះតែជ្រាបរបស់ពិត ៤ យ៉ាង គឺ ទុក្ខសច្ចៈ ១ សមុទយសច្ចៈ១ និរោធសច្ចៈ១ មគ្គសច្ចៈ១ នេះឯង ។

សេចក្តីមិនសប្បាយកាយ មិនសប្បាយចិត្ត ឈ្មោះថា ទុក្ខសច្ចៈ ព្រោះជារបស់ដែលសត្វអត់ធន់បានដោយកម្រពិតៗ ។

តណ្ហា សេចក្តីអន្ទះអន្ទែងចង់បាន ឈ្មោះថា សមុទយសច្ចៈ ព្រោះជាហេតុឲ្យទុក្ខកើតពិតៗ ។

សេចក្តីរំលត់តណ្ហាបាន ទុក្ខរមែងរលត់ទៅអស់ ឈ្មោះថា និរោធសច្ចៈ ព្រោះជាសេចក្តីរលត់ទុក្ខដោយពិត ។

មគ្គប្រកបដោយអង្គ៨ មានសម្មាទិដ្ឋិជាដើម ជាដំណើរ ឬជាឧបដិបត្តិឲ្យដល់នូវសេចក្តីរលត់ទុក្ខពិត ។ ឯមគ្គនេះ បើពោលបំព្រួញដោយខ្លីចុះមក បានដល់ សីល សមាធិ បញ្ញា ។

ដូចនេះ សត្វដែលវង្វេងមិនស្គាល់ធម៌ពិតនេះឯង ទើបវិលវល់នៅក្នុងអន្លង់វដ្តៈ គឺវិលស្លាប់ វិលកើត រាប់ជាតិមិនអស់ ។ ព្រោះសត្វលោកប្រមាទ មិនព្រមទទួលស្គាល់នូវធម៌ពិតដូចពណ៌នាមកខាងលើនេះឯង ។ ពាក្យថាប្រមាតៗនេះ បើជាភាសាធម៌មាន ២ យ៉ាង គឺ ១-បមាទៈ ប្រែថា ធ្វេសប្រហែស ២-បមាថៈ ប្រែថា មើលងាយគេ ។ ធ្វេសប្រហែស (ប្រមាទ) គឺមិនធ្វើនូវសេចក្តីល្អ មិនរក្សាសីល មិនធ្វើទាន មិនបដិបត្តិធម៌។ សង្ខារធម៌ មិនមែនកើតដោយឯងៗនោះទេ មានហេតុមានបច្ច័យផ្សំគ្នាទើបអាចកើតបាន ទោះ



ល្អក្តី អាក្រក់ក្តី ទៅតាមហេតុបច្ច័យ ដែលសត្វលោកបានសន្សំធ្វើទុក បើធ្វើសេចក្តីល្អ បានកើតទៅជាមនុស្ស ទេវតា... បើធ្វើអាក្រក់ បានកើតទៅជា សត្វតិរច្ឆាន មានឆ្កែ ឆ្មា កណ្តុរ ត្រី ជាដើម ទៅតាមសេចក្តីអាក្រក់នៃកម្មរបស់សត្វលោក ។ ចុះបើអ្នកខ្លះ មិនដែលរក្សាសីលមិនដែលធ្វើទាន ចង់បានទៅកើតឋានសួគ៌ តើទៅបានទេ ? មិនអាចទៅបានទេ ។ បុគ្គលចង់ជិះយន្តហោះ តែមិនចំណាយលុយ តើគេអាចឲ្យអ្នកនោះជិះទេ ? យ៉ាងណាមិញ ឋានសួគ៌ មិនខុសគ្នាប៉ុន្មានទេ ? រៀបរាប់មកប៉ុណ្ណេះ ឈ្មោះថា ប្រហែស (ប្រមាទ)។

ឯប្រមាថ (មើលងាយ) មិនគោរពឱនលំទោនកាយ គឺមិនបន្ទន់ឥរិយាបថ ក្រអើតក្រទម ច្រឡើសបើស ទទឹងទិស គ្មានសីលធម៌ គ្មានសុជីវធម៌នៅក្នុងប្រាណ គ្មានអបចាយនធម៌ មានភាពមានះរឹងរូស បំពាននូវសំដីធំៗ ទៅលើម៉ែឪរបស់ខ្លួន មិនខ្លាចបាប ហើយក៏មិនទទួលស្គាល់ថាមានបាបដែរ ។ ព្រះពុទ្ធជាម្ចាស់ សម្តែងថា អតិមានះ មើលងាយគេ ចាត់ថាជាកិលេសគ្រឿងសៅហ្មងក្នុងចិត្តរបស់បុគ្គល ។ ការមើលងាយអ្នកដទៃក្តី ការលើកខ្លួនឯងសង្កត់សង្កិនគេក្តី មានសេចក្តីដូចគ្នា ។ កិលេសប្រភេទនេះ កាលកើតឡើងហើយ រមែងជាហេតុឲ្យកើតទំរើសខ្លួន ដំកើងខ្លួន មើលឃើញអ្នកដទៃសុទ្ធតែថោកទាប ឬអន់ជាងខ្លួន ឬកាលបើមានសេចក្តីស្អប់ខ្ពើមអ្នកដទៃកើតឡើង រមែងគិតច្រានអ្នកដទៃឲ្យធ្លាក់ទៅក្នុងឋានៈដ៏ថោកទាបទៅក៏មាន ។ មនុស្សប្រភេទនេះ ចូលក្នុងបទថា ជាអ្នក

ដំកើងយស លើកកំពស់តែខ្លួនឯង អ្នកមានចិត្តពោរពេញទៅដោយអតិមានះហើយ រមែងជាហេតុឲ្យសម្តែងអាការនៃកាយវាចា ខុសពីប្រក្រតីដើម ។

ដូចនេះ លោកអ្នក កាលបើបានដឹងហើយ មិនត្រូវប្រមាទ ត្រូវមានការប្រឹងប្រែងធ្វើនូវសេចក្តីល្អ កាលព្រះសម្មាសម្ពុទ្ធ ហៀបនឹងបរិនិព្វាន ព្រះអង្គ មានពុទ្ធដីកាទៅកាន់ព្រះអានន្ទត្ថេរថា **អប្បមាទេន សម្បាទេថ** អ្នកទាំងឡាយ ចូរញុំាងនូវសេចក្តីមិនប្រមាទឲ្យដល់ព្រម ។

សេចក្តីអធិប្បាយដោយសង្ខេបមកប៉ុណ្ណេះ បញ្ជាក់ឲ្យឃើញថា បុគ្គល កាលបើភ្លើងមោហៈ ឆេះក្នុងសន្តានហើយ រមែងធ្វើនូវសេចក្តីអាក្រក់គ្រប់យ៉ាង ដូចពណ៌នាមកនេះ ។

អាត្មាភាព សម្តែងធម៌ទេសនា ល្មមសមគួរដល់ពេលវេលាមុននឹងបញ្ចប់ តាងនាមលោក អ្នកពុទ្ធបរិស័ទទាំងឡាយ សូមឧទ្ទិសកុសលជូនចំពោះវិញ្ញាណនៃ ឧបាសិកា ម៉ៅ សរិតា សូមអនុមោទនាទទួលយកនូវឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត ហើយសូមបានទៅកើតទីស្ថាន ដែលប្រកបដោយសេចក្តីសុខចំរើន តាមសេចក្តីគាប់ចិត្តកុំបីខាន។ ធម៌ទេសនា ក៏ល្មមសមគួរនឹងបញ្ចប់តាមកាលវេលា **ឯវំ** ៕

ថ្ងៃព្រហស្បតិ៍ ទី៨ ខែធ្នូ ២០០៤



## ធម្មទេសនា

សម្តែងដោយ ភិក្ខុ សារ សាស្ត្រ

ក្នុងឱកាសបុណ្យ ទក្ខិណានុប្បទាន៧ ថ្ងៃ ឧទ្ទិសកុសលចំពោះឧបាសិកា ម៉ៅ សរិតា កាលពីថ្ងៃសៅរ៍ ទី ១១ ធ្នូ ឆ្នាំ២០០៤ ។

សេចក្តីសង្ខេប មានដូចតទៅ –

ទក្ខិណានុប្បទាន* “អំណោយដែលគេឧទ្ទិសផលនៃទក្ខិណាទានចំពោះទៅបុគ្គលដែលទៅកាន់បរលោកហើយ... ។ យើងអាចធ្វើការសិក្សាទៅលើពាក្យទក្ខិណា ដែលជាគុណនាម ខាងស្តាំ ខាងត្បូង ។ បើយើងសិក្សាទៅលើពាក្យអំណោយ ដែលគេឧទ្ទិសផលនៃទក្ខិណាទាន ចំពោះទៅបុគ្គលដែលទៅកាន់បរលោកហើយនោះ ដូចជាមាតាបិតា បុត្រធីតា ដែលជាគ្រួសារមួយរស់នៅ មាតាបិតា ជាទិសខាងមុខខាងកើតនោះ ក៏ព្រោះមាតាបិតាជាអ្នកកើតមុនកូន និងបានចិញ្ចឹមកូនមកមុនមនុស្សដទៃទាំងអស់ ដូចព្រះអាទិត្យរះឡើងពីទិសខាងកើតជាមុនដូច្នោះ។ ទិសខាងមុខ ខាងកើត គឺមាតាបិតា បុត្រធីតា គប្បីបដិបត្តិ ដោយស្ថាន៥យ៉ាង** គឺតាំងចិត្តថា : ១-លោកបានចិញ្ចឹម

---

* អក្ខរានុក្រមខ្មែរ, ពី ក ដល់ អ និងពាក្យរាយបោះពុម្ព លើកទី១ ចំនួន៥០០០ ច្បាប់ នួន ប៊ុត ប្រមូលរៀបរៀង, ការផ្សាយរបស់បណ្ណាគារ ប៊ុត នាង, លេខ ១០ វុក្ខវិថីអាលបែរត៍ ទី១ ក្រុងភ្នំពេញ ព.ស. ២៤៩៧, គ.ស. ១៩៥៤ ។

** សូមមើលនៅក្នុងព្រះបាឡីបិដក,

ខ្លួនមកហើយដោយយ៉ាងណា ខ្លួនត្រូវចិញ្ចឹមលោកយ៉ាងនោះវិញ, ២-ជួយធ្វើកិច្ចការរបស់លោក, ៣-តាំងវង្សត្រកូលមិនឲ្យសាបសូន្យ, ៤-បដិបត្តិខ្លួនឲ្យសមគួរជាអ្នកទទួលមរតក, ៥-កាលលោកចែកស្ថានទៅហើយ បំពេញទក្ខិណាទាន ឧទ្ទិសផល ដល់លោក ។ សិក្សាកថាពីទក្ខិណានុប្បទាន*** ជានាទី ជាកិច្ចការដ៏ចំបាច់សំខាន់ ដែលមនុស្សនៅរស់ ត្រូវប្រារព្ធចំពោះបុគ្គលដែល ទៅកាន់បរលោកហើយនោះ ។

---------------------------

*** ភិក្ខុ សារ សាស្ត្រ ព.ស. ២៥៤៨ គ.ស. ២00៤ វ.ព.ប.ឱ.

៙❁៚



## អលព្ភនីយធម៌

ធម៌មួយក្នុងពួកគោលធម៌ប្រាំ　　ដែលយើងបានចាំតមកថា
ទោះបីសមណព្រាហ្មណ៍ទេវតា　　ព្រហ្មឬមារាផងឯទៀត ។
មិនអាចប្រាថ្នាបានសម្រេច　　ទោះស្ដេចមន្ត្រីឬពួកញាតិ
ធំប៉ុនណាក្ដីកុំបីឆ្ងៀត　　ប្រឹងប្ដូរធម្មជាតិនេះសោះឡើយ។
អ្វីដែលធ្លាប់ចាស់ធ្លាប់ជរា　　ធ្លាប់ឈឺធ្លាប់ជាធម្មតាហើយ
ធ្លាប់ងាប់ធ្លាប់ស្លាប់ណា៎អ្នកអើយ　　ធ្លាប់អន់ចុះថយជាប្រក្រតី ។
ធ្លាប់តែវិនាសនិរាសបង់　　ពោលដោយត្រង់ៗតាមអត្ថន័យ
ធ្លាប់ទាំងប្រាំហ្នឹងកុំប្រឹងអី　　ទៅស្ដីអង្វរថាសូម“កុំ” ។
កុំចាស់កុំឈឺកុំស្លាប់រ៉ឺ　　កុំវិនាសអីអាណិតខ្ញុំ
ស្រែកបែកដើមទ្រូងខ្វងដីសុំ　　ក៏“កុំ”នេះវាមិនព្រមទេ ។
ចង់ស្ដីៗទៅស្រេចតែចិត្ត　　ចង់គិតៗទៅឬចង់ជេរ
គេប្រឹងតែធ្វើការផងគេ　　គ្មានទេរឿងយោគយល់ដល់យើង។
ត្រូវចាស់គេរុញចាស់ឲ្យភ្លាម　　ស្បែកជ្រីវរវាមទាំងដៃជើង
ត្រូវឈឺឲ្យឈឺក្ដៅដូចភ្លើង　　ឲ្យស្លាប់ក៏យើងមិនអាចគេច ។
ពេលត្រូវចុះថយឲ្យថយភ្លែត　　តាមហេតុបច្ច័យលៃទុកស្រេច
ជាស្វ័យប្រវត្តិដោយមិនបាច់　　ចាំយើងសម្រេចព្រមមិនព្រម ។
ដល់ថ្ងៃថានឹងត្រូវវិនាស　　កុំជៀសទៅណាហួសពីល្មម
បើជៀសខ្លាំងពេកទាល់ស្គាំងស្គម　　កើតទ្រមនាំជាប់ពាក្យនិន្ទា ។
ម៉េចក៏ប្រាថ្នាផងមិនបាន　　ចិត្តអីសាមាន្យគ្មានមេត្តា

ចិត្តចោរកំណាចកាចឬស្សា　　អ្នកណាគេទៅជាមេខ្លោង ។
បានជាសម្បើមឆ្អើមហួសហេតុ　　វាយឬកត្រដែតមិនឆ្អែតកោង
កាចមានអំណាចមិនអាចតោង　　បែបកោងដូចក្តោងយោងនឹងខ្យល់។
ចម្លើយឆ្លើយប្រាប់មកវិញថា　　អ្នកដែលប្រាថ្នាក្នុងសាកល
សុទ្ធតែកើតឡើងចេញចាកផល　　សង្ខារបានផ្តល់ប្រគល់ឲ្យ ។
កាលណាសង្ខារលូកដៃចូល　　ច្បាស់ជាប្រមូលខ្មេចខ្ទីហើយ
ឥតកោតញញើតអ្នកណាឡើយ　　លោកអើយគេទាញចូលច្បាប់គេ ។
ច្បាប់គេទៀងណាស់គួរធុញទ្រាន់　　គេដាក់ទោសទណ្ឌគ្មានទំនេរ
មិនចេះអត់ឱនយោគយល់ទេ　　រាល់រូបយើងគេគេចមិនបាន ។
ពេលចាស់ឲ្យចាស់ឈឺឲ្យឈឺ　　ពេលស្លាប់ក៏គឺគេរុញច្រាន
ឲ្យទាល់តែខាងស្លាប់មិនខាន　　គ្រប់រូបគ្រប់ប្រាណគ្មានចន្លោះ ។
បើគេចង់ឲ្យខ្សោយថយថោក　　ហ្នឹងស្រេចតែលោកអីហ្នឹងនោះ
ពេលឲ្យវិនាសក៏ដូច្នោះ　　លោកទាញយើងចុះជួបវិនាស ។
បើឃើញត្រឹមតែការចុះចាញ់　　តើគួរស្រឡាញ់វាឬជៀស
តាមយោបល់ខ្ញុំថាត្រូវវាស　　កៀសវាចេញចោលកុំឲ្យសល់ ។
យកម្តងបន្តិចម្តងបន្តិច　　បូតក្តិចឲ្យអស់ពីឬសគល់
កុំឲ្យសង្ខារអាចនៅផ្តល់　　ឲ្យខ្វល់កើតចាស់ឈឺស្លាប់បាន ។
បើធ្វើទៅបានយ៉ាងនេះហើយ　　អ្នកអើយច្បាប់គេទាំងប៉ុន្មាន
មិនអាចអនុវត្តនាំរំខាន　　ដល់រូបដល់ប្រាណយើងបានទេ ។
តើមានវិធីធ្វើដូចម្តេច　　ជាកិច្ចឲ្យផុតពីច្បាប់គេ



ឆ្លើយតាមព្រះពុទ្ធថាមានតែ　　ហែរសីល សមាធិ បញ្ញា ។
សីលគឺជាការវៀរបាបកម្ម　　ចាប់ពីសីលប្រាំប្រាំប្រការ
ជៀសកម្មអាក្រក់មានបាណា　　តាមកាយវាចាឲ្យស្រឡះ ។
សីលបានបរិសុទ្ធលុះត្រាតែ　　ប្រឹងរក្សាថែឲ្យជាក់ច្បាស់
តាមសមាធិខំឲ្យណាស់　　ឲ្យជួយជម្រះចិត្តខ្វក់ខ្វល់ ។
នៅត្រឹមប៉ុណ្ណឹងមិនទាន់គ្រប់　　ត្រូវចូលប្រសព្វឲ្យបានដល់
ទៅថ្នាក់បញ្ញាមេកុសល　　ដែលផ្តល់បានតាមវិបស្សនា ។
រំលើងកិលេសទាំងថ្មីចាស់　　ចេញឲ្យស្រឡះចាករូបា
ម្តងមួយម្តងមួយរាល់វេលា　　ទីបំផុតវារលើងអស់ ។
ពេលហ្នឹងហើយយើងហ៊ានចំអក　　ឲ្យធម្មជាតិដកច្បាប់គេចុះ
មុខជាគេមិនទទឹងទាស់　　ហើយដោះយើងពីទាសៈគេ ។
សម្រេចនិព្វានគ្មានសង្ស័យ　　ផុតឥតអាល័យភពបីទេ
ចប់រឿងចប់រ៉ាវទុក្ខគ្មានល្ហែ　　មច្ចុរាជក៏ដែរលែងជួបទៀត ។
បន្ទាប់ទៅនេះខ្ញុំសូមបក　　បើកវង់ក្រចកស៊កជ្រកជ្រៀត
និយាយរឿងសង្ខារជូនញាតិ　　ដោយឆ្មៀតវែកញែកពីអត្ថន័យ ។
មនុស្សសត្វទាំងឡាយផងនានា　　កើតឡើងដោយសារការផ្សំលៃ
បញ្ចូលធាតុបួនភ្លើងទឹកដី　　ខ្យល់ជាដើមអីបានរូបរាង ។
បើកាលណាត្រូវថែមឲ្យមាន　　នូវដួងវិញ្ញាណអាចស្តាប់សៀង
សម្លេងភ្លេងភ្លាត់ឬអាចច្រៀង　　អាចឲ្យដៃកៀងបាយចូលមាត់ ។
ឲ្យជើងលើកដាក់ដើរទៅមុខ　　ឲ្យជៀសគ្រលុកគម្រង់វត្ត

ឲ្យភ្នែកមើលឃើញរូបស្គមធាត់ ឲ្យចិត្តគិតស្នាត់រុញមាត់ស្តី ។
សង្ខារធុនបែបរបៀបនេះ តាមចេះហើយពោលជាបាលី
ព្រះពុទ្ធដីកាព្រះជិនស្រី ស្តីថាឧបាទិន្នកៈ ។
សង្ខារប្រកបរូបវិញ្ញាណ ហើយមានឧទាហរណ៍ជាក់លាក់
ជាសត្វជាមនុស្សដូចលោកអ្នក ទេព្តាទេព្រ័ក្សយក្សអាសុរា ។
ចេះចាស់ចេះឈឺឬក៏ស្លាប់ មិនអាចគេចច្បាប់ធម្មជាតា
ចេះថយទ្រុឌទ្រោមវិនាសា ចេះទាំងតវ៉ាគ្រាចុកចាប់ ។
សង្ខារម្យ៉ាងទៀតឥតវិញ្ញាណ តែមានគោលប្រាំហ្នឹងស្របច្បាប់
ចាស់ឈឺខ្សោយថយវិនាសស្លាប់ សូមប្រាប់ថាមានឈ្មោះប្រចក្ស ។
តាមបទបាលីដូចតែគ្នា ជាអនុប្បាទិន្នកៈ
សង្ខារដែលគ្មានវិញ្ញាណដាក់ ជាប់ក្នុងរូបៈថ្នាក់ឃើញបាន ។
គេក៏ចេះចាស់ឈឺស្លាប់ដែរ ទ្រុឌទ្រោមហួរហែវិនាសប្រាណ
លំដាប់តាមច្បាប់ពីបូរាណ តែគេមិនបានប្រកែកអ្វី ។
គេមិនយំស្រែកឲ្យឮទេ ស្ងាត់ៗគ្នាគេៗលកលៃ
តាមច្បាប់ធម្មជាតិមិនឃ្លាតអី មិនឃើញភិតភ័យដូចយើងឡើយ។
ត្រង់ហ្នឹងគួរយើងរំពឹងគិត ប្រឹងសម្រេចចិត្តណា៎អ្នកអើយ
ជួបរឿងណាជៀសពុំរួចហើយ ណ្ហើយព្រមតាមច្បាប់ធម្មជាតិចុះ។
ជាជាងយំយែកបែកអាកាស បើជ្រុលឆាប់ផ្លាស់ហើយរំដោះ
ចិត្តចេញពីក្តីសោកស្រណោះ រូបអង្កត់អុសឥតខ្លឹមសារ ។
ត្រូវពិចារណាព្រះត្រៃលក្ខណ៍ ជឿជាក់ថាគ្រប់ៗរូបា



មិនផុតទុក្ខៈអនិច្ចា និងអនត្តាបីនេះឯង ។
មានរូបមានទុក្ខជាធម្មតា គ្រប់រូបអាត្មាមិនបាច់ថ្លែង
រឿងផ្លាស់រឿងប្តូរនាំចំបែង នេះឯងតែងតែជួបប្រទះ ។
ព្រោះអីរាល់រូបរាល់អាត្មា ជាអនត្តាប្រាកដណាស់
មើលចុះមនុស្សយើងទោះក្មេងចាស់ មិនដែលឃើញឈ្នះរូបនេះបាន។
មិនចង់ឲ្យចាស់ចេះតែចាស់ មិនចង់ព្រាត់ប្រាសគង់ព្រាត់ប្រាណ
មិនចង់ឲ្យឈឺនាំរំខាន គង់តែឈឺបានគ្មានយល់យើង ។
មិនចង់ឲ្យស្លាប់ចេះតែស្លាប់ ដោយមិនបាច់ប្រាប់អ្នកថ្កុំថ្កើង
យ៉ាងណាក៏ដោយគង់តែប៉ើង ធ្លាក់ទឹកចូលភ្លើងឡើងធ្លាក់ភ្នំ ។
ទោះមានរបងព័ទ្ធប៉ុនណា ទាំងគ្រឿងការពារដ៏ឧត្តម
រថក្រោះយន្តហោះឱសថផ្សំ រៀបចំយ៉ាងម៉េចក៏មិនផុត ។
បានគ្រាន់តែយូរហើយនឹងឆាប់ ត្រូវស្លាប់ក៏ស្លាប់ដូចគេលត់
ក្មេងក្តីចាស់ក្តីគ្មានកំណត់ កត់ត្រាថាចាំថ្ងៃណាទេ ។
គិតដល់រឿងនេះចេះតែនឹក ចាប់ភ្លឹកនឹកភ្នករករិះរេ
សាកសួរយោបល់ដល់យើងគេ គួរដែរឬទេរឿងរកទ្រព្យ ។
ព្រោះតាមធម្មតាមានពីរយ៉ាង គឺម្ខាងទ្រព្យស្លាប់ម្ខាងមិនងាប់
តែយើងចូលចិត្តរកចំណាប់ តែអ្វីដែលស្លាប់មិនស្ថិតស្ថេរ ។
រឿងរកសម្បត្តិចាត់ថាល្អ ជៀសវាងក្តីក្រមិនទាស់ទេ
លុះត្រាយើងមានទើបហ៊ានគ្មេរ ដាក់ទានដល់គេបានជាបុណ្យ ។

ព្រះពុទ្ធមិនបានហាមប្រាមថា　　មិនឲ្យធ្វើការរកទ្រព្យធន
គ្រាន់តែឲ្យជៀសក្តីលោភលន់　　ហួសហេតុពេកពន់នាំវិនាស ។
ដល់ការសាងល្អបវរជាក់　　បង្កើតគ្រោះថ្នាក់ដល់សីលទាន
ភ្លេចអស់អ្នកក្រដែលគ្នាបាន　　ជួយយើងឲ្យមានបានន៉ុះអី ។
បើមានទ្រព្យហើយចិត្តល្អទៀត　　គិតជៀតសង្គ្រោះអ្នកក្រក្រី
នោះរឹតតែឆើតខ្លាំងឥតបី　　អង្គព្រះជិនស្រីគង់សរសើរ ។
មានចុះរបស់ដែលតែងស្លាប់　　ហើយងាកទៅចាប់ចាត់ចែងធ្វើ
ខ្លះៗផងទៅនូវទង្វើ　　អំពើមិនស្លាប់គ្រាន់ជាយាន ។
ល្អជិះទៅកាន់ឋានបរលោក　　ជាជាងនៅឈ្លោកតែរឿងមាន
ដោយរឿងប្រវិញ្ចកេងបំពាន　　មិនហ៊ានធ្វើបុណ្យខ្លាចបង់លាភ ។
ឆ្ងាញ់ណាស់តែរឿងតែបំបាត់　　បែបអត្តទត្ថ(១)វាត់យកប្រៀប
ភ្លេចអស់ជីវិតអ្នកតូចទាប　　គិតគាបចម្រាញ់មានតែឯង ។
តើគួរបោះបង់របៀបនេះ　　ហើយរិះរេគិតត្រេរចាត់ចែង
រកទ្រព្យមិនស្លាប់មកគាត់តែង　　បំរើខ្លួនឯងខ្លះបានទេ ។
ទ្រព្យដែលមិនស្លាប់គាប់ប្រសើរ　　នោះតើវាជាទ្រព្យអីគេ
ឆ្លើយថាទ្រព្យហ្នឹងគ្មានអ្វីទេ　　មានតែព្រះធម៌នោះឯងហើយ ។
ជាទ្រព្យសម្បត្តិអមតៈ　　ប្រាកដជាក់លាក់មិនស្លាប់ឡើយ
ដូច្នេះគួរគិតកុំកន្តើយ　　អ្នកអើយសន្សំទ្រព្យហ្នឹងផង ។
ចុះតើត្រូវរកយ៉ាងម្តេចបាន　　បើមិនដឹងដានដឹងទំនង

១- ដើម្បីឲ្យស្របតាមក្បួនកាព្យ ត្រូវអានថា អាត់តាក់ទាត់ ។
គឺពាក្យអត្តទត្ថភាព មានន័យថាគិតតែប្រយោជន៍ផ្ទាល់ខ្លួន ។



រូបរាងប៉ុនណាសូមសាសង　　អើ!ម្តងនេះស្តាប់សព្ទសេចក្តី ។
ថាការសាងនូវអំពើល្អ　　ប្រសើរតាមធម៌ដ៏ប្រពៃ
ឲ្យច្រើនៗឡើងរៀងរាល់ថ្ងៃ　　ទាល់ក្លាយបានជាគុណសម្បត្តិ ។
ថ្លាថ្លៃល្បីល្បាញពេញភូមិស្រុក　　បានផ្តល់ក្តីសុខដល់មនុស្សសត្វ
ទាំងឡាយទាំងពួងនោះមិនស្លាត់　　សម្បត្តិយ៉ាងនេះមិនងាយស្លាប់ ។
តែងរស់រវើកឥតសៅហ្មង　　តកូនចៅផងជាលំដាប់
អង្វែងទៅឆ្ងាយសាយសូរសព្ទ　　តែងរាប់រៀងបានច្រើនតំណ ។
សម្បត្តិយ៉ាងនេះនែអ្នកអើយ　　ម្ចាស់ស្លាប់បាត់ហើយនៅបន្ត
ឲ្យផលហូរហៃតែល្អៗ　　ពីលោកីយ៍តដល់បរលោក ។
សង្ខេបសេចក្តីន័យពាក្យពេចន៍　　ចេញលេចចងបានជាពាក្យស្លោក

ស្តីពីរឿងរ៉ាវកើតទុក្ខសោក　　បក់បោកក្នុងភពលោកទាំងបី ។
វីក្តីប្រាថ្នាការចង់បាន　　ប្រាំយ៉ាងដែលមានជាបាលី
ប្រែជាសម្រាយក្លាយសេចក្តី　　ថាមិនបានអីដល់អ្នកណា ។
រៀបរាប់ខ្លីៗពីខាងលើ　　ទៅតាមដំណើរបែបធម៌អាថ៌
ជាពាក្យកំណាព្យកាព្យឃ្លោងឃ្លា　　ពីខ្ញុំអ្នកជាមិនប្រសប់ ។
បើមានលើសលស់ខ្វះសេចក្តី　　បកស្រាយអត្ថន័យលែមិនគ្រប់
ខ្ញុំមានត្រឹមតែម្រាមដៃដប់　　ប្រសព្វប្រណម្យផ្តុំវន្ទា ។
សូមលោកសន្តោសប្រោសប្រណី　　ទិតៀនក្នុងន័យស្ថាបនា
ខ្ញុំព្រមទទួលដោយជ្រះថ្លា　　គ្រាន់បានផ្សំគ្នាឲ្យបានល្អ ។

ដូច្នេះខ្ញុំសូមពោលគោរព បញ្ចប់សេចក្តីដោយស្មោះសរ
ត្រឹមប៉ុណ្ណឹងចុះព្រោះពេលក៏ ល្មមផ្អាកបន្តប៉ុណ្ណេះសិន ៕

និពន្ធដោយ លោក ខៀវ ឡេង

## ជីវប្រវត្តិ

លោកស្រី ខៀវ ឡេង នាមដើម ម៉ៅ សរិតា កើតពីថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៣៤ នៅក្រុងភ្នំពេញ ។

កាលនៅពីកុមារី បានសិក្សានៅសាលាបឋមសិក្សាសុធារស បន្ទាប់មក បានបន្តការសិក្សាតទៅទៀតនៅ អនុវិទ្យាល័យនារី ក្រុងភ្នំពេញ លុះបានចប់ការសិក្សានៅអនុវិទ្យាល័យនេះហើយ បានបំពេញមុខងារជាគ្រូបង្រៀន នៅខេត្តកំពតនិងនៅភ្នំពេញ ។

-បានរៀបអាពាហ៍ពិពាហ៍ ជាមួយលោក ខៀវ ឡេង កាលពីឆ្នាំ១៩៦១ ។

-មានកូនប្រុស ស្រី ៩នាក់ ស្លាប់អស់ ៧ នាក់ នៅ សល់សព្វថ្ងៃ ពីរនាក់គឺ កូនប្រុស ១ នាក់ និង កូនស្រី ១ នាក់ ។

នាសម័យសាធារណរដ្ឋ បានចេញពីប្រទេសខ្មែរ មករស់នៅស្រុកបារាំង ។



បានធ្វើការនៅរោងចក្រ អេឡាក់ ELAC ធ្វើគ្រឿងសម្ភារៈអគ្គីសនី សម្រាប់វិទ្យុទូរទស្សន៍ នៅភូមិទកស៊ី ។

បន្ទាប់មក បានចូលធ្វើជានិយោជិតទទួលខុសត្រូវផ្នែកមួយ នៅរោងចក្រផលិតសូកូឡា ម៉ឺនីញ៉េ សូកូឡា រោនទ្រី ម៉ាកគីនតុស សូកូឡា ណេស្តឡេ រៀងរាបរហូតដល់ពេលចូលនិវត្តនៅឆ្នាំ១៩៩៩ ។

តែងបានចូលរួមក្នុងកិច្ចការសង្គមកិច្ច ជួយសហគមខ្មែរ មានការ ចិញ្ចឹមញាតិមិត្រ ក្មេងកំព្រា និងបានបំរើ សមាគមឧបត្ថម្ភ ពុទ្ធសាសនាខ្មែរ ក្នុងការកសាងវត្តពោធិវង្ស ដោយចាប់ផ្តើមជាដំបូងឡើងនៅភូមិ បាញើ មុននឹងផ្លាស់មកតាំងជាស្ថាពរនៅភូមិ សង់សៀ ម៉ាន សព្វថ្ងៃនេះ ។

បានបំរើសមាគមពីដំបូងជាសមាជិកធម្មតាៗរហូតដល់ទីបំផុត សុខចិត្តចូលជាសមាជិកសមាគមឧបត្ថម្ភពុទ្ធសាសនាខ្មែរ រហូតដល់មានឋានៈ ជាអនុប្រធានសមាគម ។

បានខិតខំយកចិត្តទុកដាក់អស់ពីដួងចិត្ត មិនគិតការនឿយហត់ ហើយបានជាទីស្រឡាញ់រាប់អានដល់អ្នកផង ។

បានទទួលអនិច្ចកម្ម យ៉ាងឆាប់រហ័សគួរឲ្យស្តាយជាទីបំផុត កាលពីថ្ងៃសៅរ៍ ទី៤ ខែធ្នូ ថ្មីៗនេះ វេលាម៉ោង៩.០០ ព្រឹក ដោយពុំមាននរណាដឹង ឬនឹកស្មានទុកជាមុនសោះ ។

# Traduction

**PREMIER SERMON**

**(délivré en Cambodgin par Bhikkhu Ngin Phén)**

Suit une prière en hommage à Bouddha :

***Namo tassa bhagavato arahato samma sambuddhassa***

Mercredi 8 Décembre 2004.

Aujourd'hui, son époux, ses enfants, ses petits-enfants et ses proches commémorent la disparition de Madame Khieu née Mao Sarita, survenue le samedi 4 dernier, vers 9 heures du matin, due à l'échéance de l'âge. Elle s'est éteinte, paisiblement dans son sommeil, sans souffrir. Rien ne laissait présager cet événement.

Il me revient à présent de délivrer un sermon. Demain, la dépouille mortelle sera convoyée au crematorium de Père Lachaise.. Là, un sermon sera également délivré. Le samedi 11, lors de la commémoration des 7 jours du décès, en cette pagode Bodhivansa, un autre sermon sera délivré.

Je vais vous entretenir maintenant d'un enseignement de Bouddha tel que consigné dans le Suttantapitaka Anguttara nikāya Pancakanipāta: l'Alabbhaniyathāna ou l'Alabbhaniyadhamma. Cet enseignement se rapporte à «ce qu'un individu ne pourrait espérer voir se réaliser».
L'individu, quel qu'il soit, moine, brahmane, ange, démon ou simple être vivant sur cette terre, ne pourrait espérer:

1- ne pas vieillir ou ne pas voir des objets dépérir;

2- échapper aux maladies;



3- se soustraire à la mort;

4- s'opposer à la régression ou à la décrépitude;

5- aller à l'encontre du processus du délabrement ou de la disparition complète des choses.

Ce qui devra arriver arrivera. Qu'on soit moine, brahmane, ange, démon ou simple individu, personne ne saurait s'affranchir des cinq vérités qui précèdent.

Vieillir, souffrir, mourir, dépérir, disparaître. Ceci peut toucher n'importe quel être ou toucher n'importe quel objet, aussi bien ici-bas que dans un autre monde. Il est difficile d'énumérer les êtres et les choses concernés. Ils sont très nombreux. Ils peuvent être, toutefois, d'après le canon bouddhique, répertoriés en deux catégories:

1- Uppādinnaka Sangkhāra: les entités dotées d'une âme, d'une conscience. Il en est ainsi notamment des êtres humains et des animaux;

2- Anuppādinnaka Sangkhāra: les entités dépourvues d'âme ou de conscience. Il en est ainsi notamment des choses ou des objets tels qu'une maison, une charrette ou une voiture.

Ces deux catégories d'entités se distinguent par le fait que les premières peuvent exprimer leurs souffrances ; les secondes, une maison par exemple, périclitent en revanche, en silence, sans émettre le moindre souffle.

Les êtres humains ne peuvent jamais échapper à la vieillesse, à la souffrance, à la mort, au dépérissement ni à la disparition, qu'ils se cachent dans les cieux, dans les océans, dans les grottes ou n'importe où d'ailleurs.

De ce qui précède, la disparition de Mme Mao Sarita est conforme à l'ordre naturel des choses. Si ce n'est pas aujourd'hui, ce sera un peu plus tard. Elle ne peut s'affranchir en aucun cas de cette normalité, ce que Bouddha appelle l'Alabbhaniyadhamma.

Qu'on soit jeune, vieux, ignorant, instruit, pauvre, riche, simple homme du peuple, mandarin, monarque, laïc, religieux, moine parvenu au stade de l'éveil ou même au stade de l'illumination comme Bouddha, tout le monde ne peut espérer se soustraire à la vieillesse, à la souffrance, à la mort, au dépérissement ni à la disparition. La différence réside seulement dans le fait :

-qu'un profane souhaite toujours pouvoir échapper à ces cinq maux ; qu'il se lamente éperdument sur son sort lorsqu'il s'aperçoit de l'inanité de ses souhaits ;

-qu'une personne instruite ne se comporte pas de cette manière et que, le moment venu, elle sait appréhender la situation comme étant dans l'ordre naturel des choses.

Le roi Munda de Patalipoutra, peu instruit et plein d'envie, sombrait dans de profondes douleurs à la mort de son épouse, la reine Bhadradevi. Il faisait construire un sarcophage en fer et faisait immerger le corps de la défunte dans un bain d'huile pour le conserver. Il n'honorait plus ses



obligations royales. Il refusait de se nourrir. Mais, après avoir écouté l'Abbhaniyadhamma délivré par le moine Narada, ayant compris la réalité des choses, il ordonna que fût incinérée la dépouille mortelle de la reine.

Plus on est ignorant, plus on est plein d'envie, plus on souffre.

Plus on s'affranchit de l'ignorance et de l'envie, moins on souffre.
Mais, une fois l'ignorance et l'envie totalement débarrassés, on ne souffre plus.

Mesdames, Messieurs les fidèles,

L'être humain est sujet à la vieillesse, à la souffrance, à la mort. Cela est tout à fait naturel. Il est tout aussi naturel qu'il recherche ce qui est dans cet ordre normal des choses et non le contraire.

Mariage, richesse, propriété, tout est sujet au dépérissement. Seul, le Dhamma y échappe. Bouddha n'interdit pas la recherche des richesses. Il n'enseigne pas aux gens de se complaire dans la pauvreté, mais il leur recommande de rechercher le Dhamma. Autrement, ils ne pourraient pas se soustraire à la vieillesse, à la souffrance ou à la mort.

Mesdames, Messieurs les fidèles,

Mon prêche, eu égard au temps dévolu, touche à sa fin. Mais, avant de terminer, au nom de la famille de Mme Khieu Sarita, je voudrais dédier les mérites découlant du présent office à sa mémoire. Qu'elle ne connaisse que bonheur infini, sérénité et la paix.

Ainsi se termine mon prêche.



# Traduction

## DEUXIEME SERMON

**(délivré en Cambodgin par le Vénérable Bhikkhu Pich Samon)**

**Jeudi 9 Décembre 2004**

A l'occasion de la cérémonie d'incinération de la pieuse Mme Khieu née Mao Sarita, il est prévu la délivrance d'un sermon et il me revient de le faire. Aussi vous prié-je, Mesdames et Messieurs les fidèles, de bien vouloir me prêter une oreille attentive.

Suit une prière en hommage à Bouddha :

***Namo tassa bhagavato arahato samma sambuddhassa***

Après cet hommage, je vais vous entretenir d'un enseignement de Bouddha.

S'adressant aux moines, ses disciples, Bouddha explique que couvent, en nous, trois "feux":

- en premier lieu, le feu du désir: il consume ceux qui s'adonnent à la perversion du plaisir des sens;

- en deuxième lieu, le feu de la colère: il amène ceux qui en nourrissent à tuer des êtres vivants;

- en troisième lieu, le feu de l'obscurantisme: il pousse les ignorants à récuser les connaissances et la culture.

Ceux qui ne sont pas conscients de la nocivité de ces feux, les entretiennent et pavent le chemin vers l'enfer, la bestialité, le satanisme et l'aveuglement. Ils vont droit dans les bras du démon.

Mesdames, Messieurs les fidèles,

Le feu engendre naturellement une chaleur intense, mais le désir brûle intérieurement les êtres que nous sommes beaucoup plus vivement que ne le fait le feu.

Le feu qui se propage est source de lumière et de chaleur. On peut le voir, le sentir par des brûlures, mais, en faisant attention, on parvient à éviter des dégâts pouvant être causés D'ailleurs, même faute d'attention, ces dégâts ne sont que ponctuels et momentanés. En revanche, le feu du désir est inextinguible et est de loin plus destructeur.

Le feu de la colère consume les êtres, les pousse à attenter à autrui, à tuer. Il réside en leur coeur. Il les conduit à commettre des erreurs ou des fautes. Touchés par une perception, par un événement ou par des paroles peu amènes, le mécontentement engendre en eux la colère.

Un individu, dans cet état et qui n'utilise pas son intelligence, sa sagesse pour évaluer la situation, commettra des impairs susceptibles de dégénérer en actes d'une gravité ascendante, et cela tant qu'il n'arrive pas à se calmer. La colère, dit Bouddha, est un facteur maléfique dans tout un chacun.

Le feu de l'obscurantisme embrase les incultes, ceux qui sombrent dans des errements et qui ne se cultivent pas.

Les errements consistent dans les égarements, dans l'ignorance du Dhamma régissant les Quatre Nobles Vérités,



à savoir comment réagir face au mal ou à la souffrance (Dukha Sacca), comment identifier leur origine (Samudaya Sacca), comment les faire disparaître (Nirodha Sacca) et comment s'y prendre pour y parvenir (Magga Sacca). En atteignant l'Eveil ou l'Illumination, Bouddha a réussi justement à comprendre en profondeur ce mécanisme. Le désir est la source du mal ou de la souffrance dans tous les êtres de ce monde. Il faut s'en éloigner.

Le chagrin, peu de gens parviennent à le contenir.
L'envie de posséder est source de chagrin.
Réussir à faire disparaître le désir c'est réussir à faire disparaître le mal, la souffrance.
Pour y parvenir, le sentier octuple à observer est composé de :

- Compréhension juste ;
- Pensée juste ;
- Parole juste et
- Action juste
- Moyen d'existence juste ;
- Effort juste :
- Attention juste
- Concentration juste ;

Ce sentier octuple se résume en trois mots : Silā (Piété, moralité) Samādhi, (Concentration) et Paññā ( Intelligence, sagesse ).

C'est parce que, dans leurs égarements, ils méconnaissent ce sentier que ces êtres vivant dans ce monde naissent, meurent et renaissent moult fois, sans répit. Cette méconnaissance résulte soit de l'indifférence, de la négligence soit du dédain:

- L'indifférence, la négligence visent ceux qui ne s'intéressent ni aux bonnes actions, ni aux oeuvres charitables ni à la pratique du Dhamma. La vie dépend, en effet, de plusieurs facteurs.

Agréable ou désagréable, elle dépend de ce que chaque individu a accompli précédemment. S’il a fait du bien, il peut naître comme être humain ou comme ange. S’il a commis beaucoup de méfaits, il peut naître comme animal: un chien, un chat, une souris, un poisson, par exemple. En tout cas, il ne saurait espérer naître au paradis. C’est comme si quelqu’un voulait voyager en avion sans en avoir réglé le prix. Il ne le pourrait jamais

- Le dédain vise ceux qui, par leur comportement insolent, hautain, méprisant, immoral et incivil, agissent de façon inconséquente, allant par exemple jusqu’à prononcer des paroles peu amènes, notamment à l’endroit de leurs parents, et ce, sans reconnaître qu’ils ont ainsi commis un méfait. Bouddha estime que le fait de mépriser les autres et le fait de se considérer comme supérieur aux autres sont deux comportements de même nature. L’individu qui adopte de tels comportements trouve qu’il est plus digne de considérations que ses semblables. Il n’éprouve à leur égard que mépris et répulsion. Il les classe dans la catégorie des êtres inférieurs. Le fait qu’il persiste dans cette attitude le pousse à perpétrer des actes contraires aux règles de la civilité.

Une fois que vous avez compris les explications qui précèdent, Mesdames, Messieurs les fidèles, vous devez éviter ces comportements et efforcer de persévérer dans l’accomplissement du bien. Peu avant sa mort, Bouddha, s’adressant à son cousin, Ananda, se prononce dans ce sens.

Eu égard au temps imparti, le développement ci-dessus touche à sa fin. Je voudrais dédier les mérites qui en découlent à la mémoire de la pieuse  Mme Khieu née Mao Sarita pour qu’elle ne connaisse, dans son autre vie, que bonheur et prospérité conformément à  ses souhaits.



Les condoléances et marques de sympathies des amis et parents

Faute de place. nous nous  excusons de n’avoir  pu les reproduire toutes dans cette brochure.

En voici quelques unes :


កេង-វ៉ាន់សាក់
សាស្ត្រាចារ្យ
KENG VANNSAK

Que votre amour
pour celle qui vous a aimé,
soit à jamais sublimé !
Je vous accompagne dans
la même traversée d’un Océan infini
de tristesse, de regrets et d’espoir.

Tél 01 39 64 86 34
16 rue Paul Messein
95 160 MONTMORENCY

K Vannsak

Monsieur Khieu Leng

Le 7 Décembre 2004

Monsieur,

Apprenant le décès récent de votre épouse, je vous prie d'accepter mes sincères condoléances ainsi que l'expression de ma plus vive sympathie.

En remontant dans un passé récent, je me souviens de l'accueil que vous et votre épouse aviez réservé à moi-même et à quelques voisins autour d'une lignée de votre pays. Je conserve donc ce souvenir de votre couple.

Veuillez agréer mes sincères salutations.

Maurice Salesse



Phnom Penh, le 24 Décembre 2004

Bien cher Lok

Au Cambodge où nous sommes actuellement nous avons appris avec grande tristesse et affliction le décès de votre très estimée et respectée épouse.

Nous regrettons de ne pouvoir participer en personne aux obsèques de sa dépouille mortelle et nous vous présentons ainsi qu'à toute votre famille nos condoléances les plus attristées et les plus émues en cette douloureuse circonstance.

Nous regrettons aussi qu'elle n'a pu accomplir jusqu'au bout sa haute mission dans notre Association (ASBK) dont le rôle de Vice Présidente qu'elle assume, est d'une grande importance surtout celui confié pour la première fois à une femme.

Avec nos sentiments les plus cordiaux

De Mr. et Mme NGAU Bingbam

A Monsieur KHIEU LENG
aux bons soins de
ASBK 101 Bd. République
77420 Champs sur Marne
FRANCE

[illegible]

Nous vous témoignons

toute notre sympathie

dans le deuil

qui vous afflige aujourd'hui.

[illegible]

…bre 2004

…se nous a
…voir vue récemment

…t cœur avec
…le monde, nous
… disparition
… à apprécier
… grande estime.
…va à tous nos
…te de premier
…t été justifiée
…ualités requises.
…nement de mon
…cé et ne peux
… J'aimerais
triste jours et
cérémonies
…cès ici-bas,
… n'arrive
…eut faire. Hélas!
…ssibles et nous

…uloureuses, ma
…ons de votre
…primons nos très

…ers vous

Dr UNG TENG

Cher Oncle,

Le départ de notre très chère Tante m'a causé bien du chagrin. Elle est partie bien trop tôt, je n'ai même pas eu le temps de lui dire combien je lui étais (et lui serai toujours) très reconnaissante pour tout ce qu'elle a fait pour moi. Je me souviens encore des bons vieux jours où j'habitais chez vous et Lok Om me traitait comme si j'étais sa propre fille. J'espère qu'elle se rendait compte combien je l'aimais.

Mon coeur se brise et ma gorge se noue à l'idée de ne plus la revoir. Elle me manque déjà beaucoup... Je ne l'oublierai jamais.

Je suis vraiment désolée de ne pas pouvoir assister à son enterrement, j'aurais vraiment voulu lui dire au revoir... Mais je suis sure qu'elle peut me voir et m'entendre de là haut. Elle est partie rejoindre Tonton Nirin, Tonton Nai Kuon, mon papa et tous les gens qui nous ont quittés.

Je sais que c'est horriblement douloureux ce qu'il nous arrive, mais il faut essayer de l'accepter. C'est ça la vie! Il n'y a rien que nous puissions faire. La seule chose que nous pouvons faire est de continuer à faire du bien aux gens qui nous entourent, car nous aussi, on partira un jour ou l'autre.

Sur ce, je vous embrasse bien affectueusement.

Votre nièce,

Nine.



9/12/2004.

Depuis bientôt 30 ans, Sarita et moi, séparées par une simple cloison, nous vivions.

Je garde d'elle l'image d'une femme souriante. Elle avait toujours un mot gentil, nous parlions de fleurs et de sa peine a ne pas pouvoir garder ici les jolies fleurs qui poussent là-bas..., et des enfants.

Nous parlions de choses « sans impalances » et pourtant, cela en avait pour nous deux.

Aujourd'hui, Sarita nous quitte. Tout doucement, sans bruit. Et ma peine est sincère de cette grande absence. 30 années bientôt de lutte de femme pour vivre, et puis, subitement, le départ, le vide.

Je pri pour sa nouvelle vie, et j'ai une pensé émue pour ceux de sa famille qui seront privés de sa présence

Sincères condoléances

à Monsieur Khieu

et ses enfants

**SEN IUN**
40/46 Av. Maurice Thorez
94200 IVRY SUR SEINE

Cher Lauk Phaaun Khieu Léng

J'ai appris avec grande tristesse la perte cruelle que vous venez d'éprouver en la personne de Votre charmante et noble épouse.

Ma femme se joint à moi pour vous présenter et à votre grande famille, nos condoléances les plus émues et attristées. Nous prions Dieu tout puissant pour que l'âme de votre regrettée épouse repose en paix éternelle jusqu'au Nirvaa, dans l'au-delà.

Cordialement : Vôtres

Monsieur et Madame
SEN IUN

Le 6 Décembre 2004



[illegible]



ឧបាសិកា ម៉ៅ សរិតា





Dear Leng

Nangkim

Dec 17-04

P.S. Telephone

*Please accept this expression of sincere sympathy on the loss of your loved one.*

Nangkim

Mme Khieu née Mao Sarita était née le 8 septembre 1934, à Phnom Penh. Elle avait fait des études à l'Ecole primaire Sotharoth, puis au Collège des jeunes filles, deux des principaux établissements d'enseignement de la capitale. Elle avait par la suite embrassé la carrière d'enseignante. Elle avait enseigné à Kampot et à Phnom Penh.

- Mariée avec M. Khieu Léng en 1961 ;
- Ayant 9 enfants dont deux, un garçon et une fille sont vivants ;

Elle avait quitté le Cambodge, à l'époque de la République, pour venir s'installer en France. Elle avait travaillé à l'entreprise d'assemblage des composants électroniques ELAC et à l'usine de fabrication des produits chocolatés, notamment Menier, Rowntree Mackintoch et Nestlé, à Torcy, et cela jusqu'à sa retraite, en 1999.

Elle avait beaucoup participé, sa vie durant, à des oeuvres sociales et charitables dans l'intérêt de la communauté khmère. Elle avait apporté, sans compter, son soutien à des personnes en difficulté, amis ou parents, et avait élevé de nombreux orphelins.

Elle avait servi avec ferveur notre Association bouddhique, depuis sa création. Elle en était même devenue Vice-Présidente. Elle était appréciée de tous, à la mesure de son infatigable dévouement et de son visage



réjouissant, illuminé par la satisfaction d'avoir fait du bien. Elle avait beaucoup contribué notamment à la construction de la Pagode Bodhivansa, depuis son établissement à Bagneux jusqu'à son installation définitive à Champs sur Marne.

Elle nous a quitté si subitement, le samedi 4 décembre dernier, vers 9 heures du matin, alors que rien ne le présageait.

## EXTRAIT de DHAMMAPADA

### I

"II m'a insulté, il s'est moqué de moi, il m'a frappé." Tant que l'on entretient de telles pensées, sa propre colère ne s'arrête pas.

Tant que la rancune demeure dans le coeur la colère demeure aussi. Mais si la rancune s'évanouit, la colère disparaît.

Si le toit est mal fait et plein de trous, la pluie tombe dans la maison; de même, un esprit mal exercé et incapable de se contrôler laisse entrer les pensées cupides.

L'oisiveté est un raccourci vers la mort; être diligent conduit à la vie; les insensés sont oisifs et les sages sont diligents.

Le fabricant de flèches s'efforce de faire des flèches droites; pareillement, un homme sage s'efforce de garder ses pensées droites.

Un esprit troublé est toujours en mouvement, allant ici et là, et il est difficile à contrôler; au contraire, un esprit tranquille demeure dans la paix: par conséquent, il est sage de garder son esprit sous contrôle.



Quel est vraiment l'ennemi d'un homme sinon son propre esprit? C'est lui en effet qui l'attire dans les mauvais chemins.

Celui qui préserve son esprit de la cupidité, de la colère et de l'erreur jouit d'une paix réelle et solide.

### II

Faire de beaux discours sans les mettre en pratique, c'est ressembler à une belle fleur sans parfum.

Le parfum d'une fleur ne va pas contre le vent. Cependant, la réputation d'un homme bon se répand dans le monde même contre le vent!

Un compagnon mauvais et fourbe est pire à supporter qu'une bête sauvage: une bête sauvage peut vous blesser dans votre corps, mais le mauvais compagnon vous blesse dans votre esprit.

Il vaut mieux être sot et le savoir que d'être sot et se croire sage.

Une cuiller ne peut goûter la nourriture qu'elle porte. De même, un sot ne peut comprendre la sagesse du sage, quand bien même il vit avec.

Un ami de bien qui vous montre vos erreurs et vos défauts et vous reproche vos actions mauvaises est aussi digne de

respect que s'il vous révélait un trésor caché.

III

Celui qui prend plaisir à recevoir une bonne instruction peut dormir en paix: son esprit en est en effet purifié.

Un charpentier cherche à faire des poutres droites; un fabricant de flèches cherche à faire des flèches bien calibrées; celui qui creuse un fossé d'irrigation cherche à faire couler l'eau doucement; de même, un sage cherche à contrôler son esprit de manière à ce qu'il fonctionne dans la douceur et la vérité.

Un grand rocher n'est pas ébranlé par le vent; de même, le coeur du sage n'est troublé ni par les honneurs, ni par les insultes.

Se contrôler soi-même est une plus grande victoire que de vaincre mille hommes dans une bataille.

Mieux vaut vivre un seul jour et entendre un bon enseignement que de vivre cent ans et n'en point entendre.

Si on s'aime soi-même, on doit veiller constamment à ne pas céder aux désirs mauvais.

IV

Evitez tout mal, cherchez le bien, gardez pur votre esprit: tel est l'enseignement des Bouddha.



La patience est une discipline des plus difficiles, mais c'est à celui qui est patient que la victoire finale est assurée.

C'est quand on est en proie à la rancune qu'il faut chasser la rancune; c'est quand on est dans la tristesse qu'il faut chasser la tristesse et c'est quand on est enclin à la convoitise qu'il faut chasser la convoitise. Pour vivre une vie généreuse, il faut se regarder soi-même comme ne possédant rien de tout ce qu’on possède.

Avoir la santé est un grand avantage ; se contenter de ce qu’on a vaut mieux que posséder de grandes richesses ; être considéré comme digne de confiance est le vrai signe de l’amitié ; atteindre l’Illumination est le plus haut bonheur.

Ne sois pas attaché à ce qui te plaît, ne repousse pas ce qui te déplaît. La tristesse, la crainte et la servitude proviennent de l’attirance et de la répulsion.

V

La rouille croît sur le fer et le ronge ; de même, le mal croît dans l’esprit et le ronge.

Un livre qui n’est pas lu régulièrement se couvre vite de poussière ; une maison qu’on ne répare pas à temps tombe en ruine ; de même, un homme qui vit dans la torpeur devient tout de suite impur.

La souillure la plus à craindre est celle de l’ignorance. On ne peut espérer purifier ni son corps ni son esprit, tant qu’on ne chasse pas l’ignorance.

Il est facile de dévoiler les erreurs d’autrui, mais c’est difficile d’avouer ses propres erreurs. On proclame tout haut les fautes d’autrui, mais on cache ses propres fautes comme un tricheur cache ses faux dés.

VI

Comme un chevalier veille à la porte du château, ainsi on doit garder son propre cœur contre les ennemis du dehors et du dedans, et ne pas se relâcher un seul instant.

VII

Si on est influencé par ses attirances et ses répulsions, on ne peut comprendre correctement la signification des circonstances et chercher à les dominer; si on est libre d'attachements, on comprend correctement les circonstances et toutes paraissent nouvelles et pleines de sens.

La bonheur suit la tristesse et la tristesse, le bonheur. C'est quand on ne fait plus de discrimination entre le bonheur et la tristesse, entre le bien et le mal, qu'on est capable d'être vraiment libre.

Se tourmenter à cause de l'avenir et avoir du regret pour le passé, c'est ressembler à des roseaux coupés qui se



dessèchent.
Le secret de la santé du corps et de l'esprit, c'est de ne pas se lamenter à cause du passé, ne pas se tourmenter à cause de l'avenir, ne pas se troubler a l'avance, mais de vivre l'instant présent avec sagesse et simplicité.

Ne t'attarde pas dans le passé, ne rêve pas à l'avenir, mais concentre ton esprit sur le moment présent.
C'est une bonne chose que d'accomplir sans faille le devoir présent: ne cherche ni à l'éviter, ni à le remettre au lendemain. En agissant ainsi, tu passeras une journée heureuse.

Il n'y a pas de meilleur guide que la sagesse, pas de meilleur compagnon que la foi. Il faut s'efforcer d'échapper aux ténèbres de l'ignorance et de la souffrance, et chercher la lumière de l'Illumination.

Quand on contrôle son corps et son esprit, cela transparaît dans des actions vertueuses. Il y a là un devoir supérieur. La foi sera alors une richesse; la sincérité donnera une douce saveur à la vie et accumuler des mérites deviendra une tâche sacrée.

Dans le voyage qu'est la vie, la foi est la nourriture, la vertu est un abri, la sagesse est une lumière durant le jour et l'attention correcte est une protection durant la nuit. Si quelqu'un mène une vie pure, rien ne peut le détruire; s'il a vaincu la convoitise, rien ne peut limiter sa liberté.

On doit s'oublier soi-même pour l'amour de sa famille; on

doit oublier sa famille pour l'amour de son village; on doit oublier son village pour l'amour de son pays: pour l'amour de l'Illumination, on doit tout oublier .

Tout change, tout apparaît et disparaît: il n'y a pas de bonheur paisible tant qu'on ne passe pas au-delà des vicissitudes de la vie et de la mort.